**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*រដ្ឋបាលព្រៃឈើ*

*នាយកដ្ឋានព្រៃឈើនិងសហគមន៍ព្រៃឈើ*

ភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤

*ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់* (MRV)

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**តាមរយៈ:** ប្រធាននាយកដ្ឋានព្រៃឈើ និង សហគមន៍ព្រៃឈើ

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) លើកទី ៣ របស់ក្រុមការងារ។

**ជូនភ្ជាប់:** -រូបថតសកម្មភាពនៃកិច្ចប្រជុំ.................................................................................ចំនួន១ច្បាប់

-បញ្ជីវត្តមាន....................................................................................................................ចំនួន១ច្បាប់

-សេចក្តីផែនការសកម្មភាពការងារ MRV..............................................................ចំនួន១ច្បាប់

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ យើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូ មេត្តាជ្រាបថា កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេស វាស់វែងរាយការណ៍ និង ផ្ទៀងផ្ទាត់ (MRV) បានរៀបចំកិច្ចប្រជុំលើកទី៣ ស្តីពីការរៀបចំផែនការសកម្មភាព MRV នៅសាលប្រជុំហាហ្គា ដែលទទួលបានលទ្ធផលដូចខាងក្រោមៈ

## I-**សមាសភាពចូលរួម**

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ១៥ នាក់ មកពីៈ

-រដ្ឋាភិបាល: រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន រដ្ឋបាលជលផល

-អង្គការក្រៅរដ្ឋាភិបាល: អភិរក្សអន្តរជាតិ(CI) អង្គការរុក្ខជាតិ និងសត្វព្រៃអន្តរជាតិ(FFI)

-ក្រុមប្រឹក្សាយោបល់: អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ(FAO) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA)សមាគមន៍ជនជាតិដើមភាគតិចកម្ពុជា (CIYA) សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA)។ (បញ្ជីវត្តមាន ដូចឯកសារជូនភ្ជាប់)

## II-**គោលបំណងនៃអង្គប្រជុំ**

របៀបវារៈសំខាន់ៗសម្រាប់កិច្ចប្រជុំ ក្រុមការងារបច្ចេកទេស វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) លើកទី៣នេះមានចំនួនពីរគឺៈ

-ធ្វើសេចក្តីណែនាំសង្ខេបលើប្រព័ន្ធវាស់វែងរាយការណ៍ និងផ្ទៀងផ្ទាត់(MRV/REL)

-ការពិភាក្សាបន្តលើផែនសកម្មភាពរបស់ក្រុម MRV

-បញ្ហាផ្សេងៗដែលពាក់ព័ន្ធ

## III-ដំណើរការកិច្ចប្រជុំ

លោក Shigeru Ono បានធ្វើបទបង្ហាញស្តីអំពីសេចក្តីណែនាំសង្ខេបលើប្រព័ន្ធវាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ (MRV/REL)។ ក្នុងបទបង្ហាញបានរៀបរាប់អំពី តម្រូវការសម្រាប់ធ្វើរបាយការសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិបញ្ជូនទៅ UNFCCC ដែលយ៉ាងហោចណាស់ត្រូវមានព័ត៌មានស្តីអំពីការប្រើប្រាស់ដី កត្តារេចរឹលព្រៃឈើ និងបម្រែបម្រួលប្រភេទដី។ កាលបរិច្ឆេទក្នុងការផ្ញើររបាយការណ៍គឺខែធ្នូ ឆ្នាំ២០១៤។ បន្ទាប់មកលោក Shigeru Ono ក៏បានធ្វើបទបង្ហាញពីផែនការសកម្មភាពការងារ MRV ដែល CAM-REDD និង UNREDD បានពង្រាងឡើងសម្រាប់ក្រុមការងារMRV ក្នុងគោលបំណងពន្លឿនលើកិច្ចពិភាក្សាលើផែនការសកម្មភាព MRV។ ទន្ទឹមនឹងនោះ ក្រុមការងារបច្ចេកទេសស្នើសុំធ្វើការដាក់បញ្ចូលផែនការសកម្មភាពពង្រាងខាងលើជាមួយនឹងលទ្ធផលផែនការសកម្មភាព ដែលក្រុមការងារលើកឡើងតាមរយៈការប្រជុំពីរលើកកន្លងមក។

ក្រុមការងារបានធ្វើការពិភាក្សាគ្នាលើប្រព័ន្ធការងាររដ្ឋបាល របស់ក្រុមការងារបច្ចេកទេស MRV។ ក្រុមការងារបានធ្វើការស្នើសុំទៅ UNREDD រាល់កិច្ចប្រជុំត្រូវមាន៖

-របៀបវារៈច្បាស់លាស់នឹងចែកជូនសមាជិកអង្គប្រជុំមុនពេលកិច្ចប្រជុំចាប់ផ្តើម

-ត្រូវមានសំភារៈ និងឯកសារសម្រាប់ប្រជុំគ្រប់គ្រាន់(ឯកសារ សៀវភៅ ប៊ិច)

-ត្រូវមានថ្លៃសេវាទំនាក់ទំនង សម្រាប់ទាក់ទងអញ្ជើញសមាជិកអង្គប្រជុំ

ចុងបញ្ចប់ លោក Ono និង លោក Sakai បានធ្វើការចែករំលែកបទពិសោធន៍អំពីគម្រូប្រព័ន្ធសារពើភ័ណ្ឌព្រៃឈើជាតិរបស់ប្រទេសកុងហ្គោ (Congo)។ បន្ទាប់មកលោក Mathieu ក៏បង្ហាញអំពីគេហទំព័រប្រព័ន្ធគ្រប់គ្រងព្រៃឈើថ្នាក់ជាតិរបស់ប្រទេសកម្ពុជា ដែលរៀបចំដោយអង្គការ FAO ជូនដល់អង្គប្រជុំ។

## លទ្ធផលនៃកិច្ចប្រជុំ

ក្រុមការងារបានចាប់ផ្តើមពិភាក្សាលើផែនការសកម្មភាព ដែលទទួលបានលទ្ធផលដូចក្នុងឯកសារជូនភ្ជាប់ គឺសម្រេចបាន៖

-ផែនការសកម្មភាពការងារ MRV លើចំណុច ៤.៤ និង៤.៥ និងសកម្មភាពលំអិត។ ចំពោះសកម្មភាព ៤.៤.៦ (កំណត់មាតិកាសម្រាប់ចងក្រងទិន្នន័យក្នុង Database) ត្រូវលើកទៅពិភាក្សាសម្រេចនៅកិច្ចប្រជុំលើកក្រោយ ពីព្រោះរង់ចាំក្រុមការងារតំណាងក្រសួងបរិស្ថាន និងរដ្ឋបាលជលផលស្នើសុំសេចក្តី សម្រេចចិត្តពីថ្នាក់ដឹកនាំ ។

-ឯកភាពលើប្រព័ន្ធការងាររដ្ឋបាលរបស់ក្រុមការងារបច្ចេកទេស MRV តម្រូវឲ្យក្រុមការងារលេខាធិការដ្ឋានរេដ+កម្ពុជាជាអ្នកទទួលបន្ទុក មានន័យថាក្រុមការងារលេខាធិការដ្ឋាន រេដ+កម្ពុជា ត្រូវទទួលរៀបចំរាល់កិច្ចប្រជុំ MRV (ទីកន្លែង ឯកសារ និងរបៀបវារៈប្រជុំ និងធ្វើកំណត់ហេតុអង្គប្រជុំ) ។

-ឯកភាពឲ្យមានការលើកបទពិសោធន៍ ការធ្វើសារពើភ័ណ្ឌព្រៃឈើផ្សេងៗគ្នា របស់អង្គកាក្រៅរដ្ឋាភិបាល រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន រដ្ឋបាលជលផល ដើម្បីស្វែងរកការឯកភាពលើទម្រង់ឡូត៏គម្រូសម្រាប់ការធ្វើសារពើភ័ណ្ឌព្រៃឈើថ្នាក់ជាតិ។

ក្រុមការងារបានរៀបចំកិច្ចប្រជុំលើកក្រោយនាថ្ងៃទី៤ ខែមីនា ឆ្នាំ ២០១៤ មួយលើកទៀតក្នុងគោលបំណងធ្វើការពិភាក្សាលើគោលការណ៍ណែនាំស្តីពីបច្ចេកទេសធ្វើសារពើភណ្ឌព្រៃឈើកម្រិតជាតិ (NFI) របាយការណ៍អំពីកិច្ច ប្រជុំនឹងដាក់ជូនរដ្ឋបាលព្រៃឈើជាបន្តបន្ទាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយអនុគ្រោះ តាមការគួរ ។

លេខ……………………នពស

បានឃើញ និង បញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

"សូមមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះ "

ភ្នំពេញ ថ្ងៃទី ខែមីនា ឆ្នាំ២០១៤

**ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ**